ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 06 / 2012
ម៉ោង (Time/Heure): 14 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បត្តិ៍ ទី ២១ ខែ មិថុនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៧៨

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី Natacha WEXELS-RISER |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក វ៉េង ហ៊ាត់, លោក Tarik ABDULHAK លោក Keith RAYNOR |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោក សំ សុខគង់, លោកស្រី Christine MAERINEAU, លោក គីម ម៉េងឃី, លោក Barnabé NEKUIE, លោកស្រី ស៊ិន សុវ៉ិន, លោក |
| សាក្សី៖ លោក ខៀវ នៅ TCW-321 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Alexandra PRASSOLOFF, កញ្ញា ជា ស៊ីវហ័ង, លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សាសម្រាប់សាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៥.៤០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ម៉ោង និង ៤០នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | ជនជាប់ចោទ អៀង សារី<br>ជនជាប់ចោទ នួន ជា | ៩.០០<br>១២.០០ | ៩.០០<br>១២.០០ |
| ការតាំងសំណួររបស់សាក្សី ខៀវ នៅ TCW-321 | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ៩.០៥<br>១៣.៤៥<br>១៥.០០ | ១៣.៤០<br>១៤.៤០<br>១៥.២០ |
| ការកត់សម្គាល់របស់មេធាវីការពារក្ដីពីភាពមិនស៊ីសង្វាក់នៃខ្សែអត្ស និង | មេធាវីការពារក្ដីលោក ខៀវ សំផន | ១៣.៤០ | ១៣.៤៥ |

| | | | |
|---|---|---|---|
| លើកំនត់ហេតុស្តាប់ចម្លើយសាក្សី | | | |
| ការតាំងសំណួរដល់សាក្សី ខៀវ នៅ TCW-321 | មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី | ១៣.៤៥ | ១៤.៤២ |
| ការលើកឡើងអំពីភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត | មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីការពារក្តី នួន ជា | ១៣.៤០<br>១៥.២០ | ១៣.៤៥<br>១៥.២៥ |
| សំណើអំពីភាពអាចទទួលយកបាននៃឯកសារ | មេធាវីការពារក្តី នួន ជា | ១៥.២៥ | ១៥.៣៥ |
| សេចក្តីសម្រេចផ្ទាល់មាត់អំពីការប្រព្រឹត្តិខុសក្រមសីលធម៌របស់មេធាវីការពារក្តី | អង្គជំនុំជម្រះ | ១៥.៤០ | ១៥.៤០ |
| ការកំណត់កាលបរិច្ឆេទសម្រាប់សវនាការបន្ទាប់ | អង្គជំនុំជម្រះ | ១៥.៤០ | ១៥.៤០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ (ជនជាប់ចោទ អៀង សារី ស្នើសុំសម្រាប់រយៈពេលពេញមួយថ្ងៃ ហើយ នួន ជា ស្នើសុំកន្លះថ្ងៃ) ។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ។

**ការតាំងសំណួរដល់សាក្សី ខៀវ នៅ TCW-321**

សហព្រះរាជអាជ្ញា បញ្ចប់ការតាំងសំណួរដល់សាក្សី បន្ទាប់មកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរដល់សាក្សី ។

**ការលើកឡើងអំពីភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត**

មេធាវីការពារក្តី ខៀវ សំផន (គាំទ្រដោយមេធាវីការពារក្តី នួន ជា) បានលើកឡើងថា វាមាននូវភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សម្លេងនៃការសម្ភាសសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ។ ហេតុដូច្នេះ មេធាវីស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធ មិនទទួលយកកំណត់ហេតុនេះ ។

**សំណើអំពីភាពអាចទទួលយកបាននៃឯកសារ**

មេធាវីការពារក្តី នួន ជា បោះបង់នូវការតាំងសំណួរដល់សាក្សី ព្រោះអង្គជំនុំជម្រះបានអនុញ្ញាតឱ្យមេធាវីប្រើតែឯកសារមួយក្នុងចំណោមឯកសារពីរសម្រាប់ការសួរសាក្សី ពោលគឺឯកសារដែលមាននៅក្នុងបញ្ជីឯកសាររបស់ភាគីណាមួយ ដែលអង្គជំនុំជម្រះបានតម្រូវ ។

**ការកំណត់កាលបរិច្ឆេទសម្រាប់សវនាការបន្ទាប់**

អង្គជំនុំជម្រះបានជូនដំណឹងដល់សាធារណៈជន និងភាគីថា តុលាការនឹងមិនធ្វើសវនាការចាប់ពីថ្ងៃស្អែក ហើយសវនាការនឹងបន្តចាប់ពីថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ ដោយស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញ David Chandler ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1681 | 5.12 | 00013269-00013352<br>00183232-00183245 | ចំលើយសារភាពរបស់ចេងអាន ជាភាសាខ្មែរនៅថ្ងៃទី០៣វិច្ឆិកា១៩៧៨<br>S-21 Confession of CHENG An, Minister of Industry | P | | | |
| E3/1682 | 5.15 | 00013660-00013990<br>00185069-00185182 | ចម្លើយសារភាពមន្ទីរ ស-២១ របស់ ជូ ជេត ហៅ ស៊ី<br>S-21 Confession of CHOU Chet alias Si | P | | | |
| E3/1098 | D248/3.12 | 00406601-00406602<br>00524161-00524161<br>00532704-00532704 | [លិខិតបញ្ជាក់ការជំនួសឯកសារ] សំបុត្រជូនអង្គការជាទីគោរព ស្នេហា ជាភាសាខ្មែរ ធ្វើដោយ ប៉ាល់ នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ១៩៧៨<br>[Surrogate Sheet] Letter To Respected and Beloved Angkar in Khmer by Pal on date 26 March 1978<br>[Feuille remplacée] Document D21202 | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/342 | D288/ 6.68.1 | 00329596-00330129 00329596-00330129 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១ [Surrogate Sheet] Annex 1: Revised S-21 Prisoner List | P | No. 1509, no. 2896 | No. 1509, no. 2896 | No. 1509, no. 2896 |
| E3/507 | D166/ 183 | 00355438-00355442 00358139-00358143 00408424-00408428 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KHIEV Noeu ខៀវ នៅ [Surrogate Sheet] Written Record of Interview of KHIEV Noeu ខៀវ នៅ [Feuille remplacée] Procès verbal d'audition de KHIEV Noeu ខៀវ នៅ | P | 00355440, 00355442 | 00358141, 00358143 | 00408426, 00408428 |
| E3/1236 | T8154 | 00187898-00187900 00631462-00631466 | របាយការណ៍ប្រចាំសប្តាហ៍ក្រសួងពាណិជ្ជកម្មស្តីពីបរិមាណស្រូវ និងអង្ករ Rapport hebdomadaire du Ministère du commerce sur les quantités de riz et de paddy | P | | | |
| E3/1232 | T8191 | 00187883-00187885 00809206-00809208 00612209-00612213 | របាយការណ៍ប្រចាំសប្តាហ៍ មានចំណងជើងថា "ស្ថិតិចូល, ចេញ និងតុល្យការ" និង "ស្រូវ និងអង្ករដែលនៅសល់ក្នុងឃ្លាំង" Weekly Reports entitled "Statistics of input, output and balance" and "Remaining husked rice and paddy in the warehouses" Rapports hebdomadaires intitulés "Nombre des entrées, des sorties et des reliquats" et "Riz décortiqué et paddy restant dans les entrepôts" | P | | | |
| E3/1228 | T8164 | 00187895-00187897 00597532-00597534 | របាយការណ៍ប្រចាំសប្តាហ៍នៅក្រសួងពាណិជ្ជកម្ម មានចំណងជើងថា "ស្ថិតិចូល, ចេញ និងតុល្យការ" និង "ស្រូវ និងអង្ករដែលនៅសល់ក្នុងឃ្លាំង" Rapports hebdomadaires du Ministère du commerce intitulés "Nombre des entrées, des sorties et des reliquats" et "Riz décortiqué et paddy restant dans les entrepôts" | P | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (សម្រាប់រយៈពេលពេញមួយថ្ងៃ) និង

នួន ជា (សម្រាប់ពេលរសៀល) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់មកកាន់បន្ទប់សវនាការវិញ (ចំណែកជនជាប់ចោទ អៀង សារី បង្គាប់ឱ្យនាំខ្លួនគាត់មកបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ប្រសិនបើគាត់លះបង់សិទ្ធិក្នុងការចូលរួមសវនាការ) ឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២។
- សេចក្តីសម្រេចផ្ទាល់មាត់អំពីការប្រព្រឹត្តិខុសក្រមសីលធម៌របស់មេធាវីការពារក្តី៖

  អង្គជំនុំជម្រះបានធ្វើសេចក្តីព្រមានទៅកាន់មេធាវីការពារក្តី ដោយអង្គជំនុំជម្រះបានកត់សម្គាល់ពីការប្រព្រឹត្តមិនត្រឹមត្រូវដែលមានលក្ខណៈស៊ីសង្វាក់គ្នារបស់មេធាវីការក្តីឱ្យជនជាប់ចោទ នួន ជា ហើយជាពិសេសគឺមេធាវីការពារក្តីអន្តរជាតិក្នុងក្រុមនេះ។ ការប្រព្រឹត្តមិនត្រឹមត្រូវនេះ រួមមាន (មិនកំរិតត្រឹមតែ) ការរំលោភដោយចេតនាលើសេចក្តីបង្គាប់នានារបស់អង្គជំនុំជម្រះ ការបញ្ចេញឯកសារសំងាត់ ឬសំងាត់បំផុតទៅសារព័ត៌មានដោយគ្មានការអនុញ្ញាត និង ការធ្វើសេចក្តីថ្លែងការណ៍នានាក្នុងតុលាការ មិនគោរពដល់តុលាការ ឬក៏មិនស្របតាមនិយាម និង ក្រមសីលធម៌វិជ្ជាជីវៈច្បាប់ដែលមានការទទួលស្គាល់ឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ សូមជម្រាបជូនដំណឹងថា អំពើនិងគំរូផ្សេងដែលមិនត្រឹមត្រូវទាំងនេះ នឹងត្រូវបញ្ជូនទៅគណៈមេធាវីជាតិដែលពាក់ព័ន្ធដើម្បីឱ្យចាត់វិធានការណ៍សមស្របអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីព្រមាននេះជាផ្លូវការ ស្របតាម វិធាន ៣៨(១) នៃវិធានផ្ទៃក្នុង និងកត់សម្គាល់ថា អង្គជំនុំជម្រះ នឹងចាត់វិធានការណ៍តាមនីតិវិធីដូចមានចែងក្នុងវិធាននោះក្រៅពីវិធានការណ៍ ដែលត្រូវចាត់ការដោយគណៈមេធាវីជាតិនីមួយៗ។

- បង្គាប់ឱ្យនាំសាក្សី ខៀវ នៅ ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ។

00820261



| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| សវនាការនឹងបន្តនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Natacha WEXELS-RISER